# អក្ខរវិធីខ្មែរ

ស្រង់យកពីសៀវភៅប្រជុំធម្មបរិយាយ

( សម្រាប់អនុសំវច្ឆរមហាសន្និបាតទី ១០ នៃមន្ត្រីសង្ឃ )

ព. ស. ២៤៩៦ គ. ស. ១៩៥៤

---


ដោយ

សម្ដេចព្រះមហាសុមេធាធិបតី

សង្ឃនាយក

( ជ. ណ. ជោតញ្ញាណោ )



A 20

# អក្ខរវិធីសង្ខេប

## ស្រង់យកពីសៀវភៅប្រជុំធម្មបរិយាយ

( សម្រាប់អនុសំវច្ឆរមហាសន្និបាតទី ១០ នៃមន្ត្រីសង្ឃ )

ព. ស. ២៤៩៦ គ. ស. ១៩៥៤

---

គហបតី បេ - យាន

បានបោះពុម្ពផ្សាយក្នុងអនុសំវច្ឆរមហាសន្និបាតទី ១៣ នៃមន្ត្រីសង្ឃ ព. ស. ២៤៩៩ គ. ស. ១៩៥៧ ម្ដងទៀត ដើម្បីបំពេញកិច្ចសិក្សានៃភិក្ខុសាមណេរដែលត្អូញថា ចង់បាន ផ្សិតសៀវភៅប្រជុំធម្មបរិយាយ ដែលបានបោះពុម្ពប្រគេនហើយនោះ ក្នុង ១ វត្ត ៗ មានតែ ១ ក្បាល ៗ មិនល្មមដល់សេចក្ដីត្រូវការ; ទាំងខាងសាលាធម្មវិន័យ ក៏ត្រូវការអក្ខរវិធីសង្ខេបនេះណាស់ដែរ ។

---

ដោយ

**សម្ដេចព្រះមហាសុមេធាធិបតី**

សង្ឃនាយក

( ជ. ណ. ជោតញ្ញាណោ )

# អក្ខរៈ

អក្ខរៈ សម្រាប់ប្រើក្នុងភាសាបាលីមាន ៤១ តួគឺ ស្រៈ ៨ តួ ព្យញ្ជនៈ ៣៣ តួ ។ ស្រៈ ៨ តួគឺ អ អា, ឥ ឦ, ឧ ឩ, ឯ(១) ឱ ។ ព្យញ្ជនៈ ៣៣ តួគឺ ក ខ គ ឃ ង, ច ឆ ជ ឈ ញ, ដ ឋ ឌ ឍ ណ, ត ថ ទ ធ ន, ប ផ ព ភ ម (ទាំង ២៥ តួនេះ ហៅថា វគ្គ); យ រ ល វ ស ហ ឡ ំ(២) (ទាំង ៨ តួនេះ ហៅថា អវគ្គ ឬសេសវគ្គ) ។

អក្ខរៈ ទាំង ៤១ តួនេះមាន ឋាន "ទីតាំងនៃកំណើតសំឡេង", ករណៈ "លំនាំនៃការធ្វើសំឡេង", ឃោសៈ "សំឡេងគឹកកង", អឃោសៈ "សំឡេងមិនគឹកកង" និង អក្ខរប្បភេទ "ប្រភេទនៃអក្ខរៈ" ប៉ុណ្ណោះជាដើម ជាគ្រឿងចំណាំ ។

## ឋាន

ឋានមាន ៦ យ៉ាងគឺ ១– កណ្ឋជៈ "មានសំឡេងកើតក្នុងក" មាន ៨ តួគឺ អ អា, ក ខ គ ឃ ង, ហៈ

---

១ មានសំឡេងជា េ (អេ) ។ ២ មានសម្លេងជា អ័ង ឬ អ័ម ហៅថា និគ្គហិត ឬ និគ្គហីត ។

២– តាលុជៈ “ មានសំឡេងកើតត្រង់ពិតាន គឺក្រអូមមាត់ ” មាន ៨ តួគឺ ឥ ឦ, ចឆ ជឈ ញ, យះ ៣– មុទ្ធជៈ “មានសំឡេងកើតនាក្បាល” មាន ៧ តួគឺ ឫ ឬ ដឋ ឌឍ ណ, រឞ; ៤– ទន្តជៈ “ មានសំឡេងកើតត្រង់ប្រទល់ធ្មេញ ” មាន ៧ តួគឺ ឭ ឮ តថ ទធ ន, លស; ៥– ឱដ្ឋជៈ “ មានសំឡេងកើតត្រង់ប្រទល់បបូរមាត់ ” មាន ៧ តួគឺ ឧ ឩ, បផ ពភ ម; ៦– នាសិកជៈ “មានសំឡេងកើតក្នុងច្រមុះ” ចំពោះតែនិគ្គហិតគឺ ំ មួយ ។ អក្ខរៈទាំងប៉ុណ្ណោះនេះ មានសំឡេងកើតក្នុងឋានតែមួយ ។ ហៅថា ឯកដ្ឋានជៈ ។

## ឋានពិសេស

អក្ខរៈក្រៅពីនេះជា ទ្វិដ្ឋានជៈ “មានសំឡេងកើតក្នុងឋាន ២” ។ ឯ និង ឱ ជា សំយុត្តសរៈ “ស្រៈផ្សំ” ; ឯ ជា កណ្ឋ-តាលុជៈ “មានសំឡេងកើតក្នុងក និង ពិតាន” ដ្បិត(ឯ)កើតពី អ និង ឥ; ឱ ជា កណ្ឋោដ្ឋជៈ “មានសំឡេងកើតក្នុងក និង ប្រទល់បបូរមាត់” ដ្បិត (ឱ) កើតពី អ និង ឧ ។ ង ញ ណ ន ម ទាំង ៥ តួនេះហៅថា វគ្គន្តៈ “ព្យញ្ជនៈបំផុតវគ្គ” ជា សកដ្ឋាន-នាសិកជៈ “ មានសំឡេងកើតក្នុងឋានរបស់ខ្លួន ។ និង

ប្រមុះ" ៗ រឺ ជា ទន្តជៈ "មានសំឡេងកើតត្រង់ប្រទល់ធ្មេញ នឹង បបូរមាត់" ៗ ហ តាមឋានដើមរបស់ ខ្លួនជា កណ្ឋជៈ ប៉ុន្តែបើផ្សំជាមួយនឹងព្យញ្ជនៈ ៨ តួគឺ ញ ណ (ន) ម, យលវឡ ដូចជា គញ្ហិ, គណ្ហា, គម្ហា, មយ្ហំ, រុល្ហំ, ជិវ្ហា, រូឡ្ហ ដូច្នេះ ក៏ក្លាយជា ឱរជៈ "មានសំឡេងកើតត្រង់ទ្រូង" ទៅវិញ, ព្រោះហេតុ នោះ អក្សរ ហ នេះ ដូនណាជា កណ្ឋជៈ ដូនណាជា ឱរជៈ ៗ

## ករណៈ

ករណៈ គឺលំនាំនៃការធ្វើសំឡេង(១) មាន ៤ យ៉ាងគឺ ១_ ជិវ្ហាមជ្ឈ "ពាក់កណ្តាលអណ្តាត" សម្រាប់ អក្ខរៈជា តាលុជៈ; ២_ ជិវ្ហោបគ្គ "រលាស់ចុងអណ្តាតចូល" សម្រាប់អក្ខរៈជា មុទ្ធជៈ; ៣_ ជិវ្ហគ្គ "ចុងអណ្តាត" សម្រាប់អក្ខរៈជា ទន្តជៈ; ៤_សកដ្ឋាន "តាមឋានរបស់ខ្លួនស្រាប់" សម្រាប់អក្ខរៈក្រៅពី តាលុជៈ, មុទ្ធជៈ, ទន្តជៈ ៗ

---

១ ថែបហាត់ធ្វើសំឡេង ឲ្យដឹងខ្នាតសម្លេងថា អក្សរណាមានសូរសម្លេងកើតត្រង់ណា ? ក៏បញ្ចេញសូរសម្លេងឲ្យបានត្រូវត្រង់ទីកើតសម្លេងនោះ ៗ ៗ

## ឃោសៈ និង អឃោសៈ

តាមលំដាប់អក្សរ ត្រូវនិយាយពីអឃោសៈមុន ។ អក្ខរៈ ១១ តួគឺ ក ខ, ច ឆ, ដ ឋ, ត ថ, ប ផ, ស នេះជា អឃោសៈ "មានសំឡេងមិនគឹកកង" គឺមានសូរសំឡេងតូច ៗ អក្ខរៈ ២១ តួគឺ គ ឃ ង, ជ ឈ ញ, ឌ ឍ ណ, ទ ធ ន, ព ភ ម; យ រ ល វ ហ ឡ នេះជា ឃោសៈ "មានសំឡេងគឹកកង" គឺមានសំឡេងធំ ៗ និគ្គហិត ជា ឃោសាឃោសវិមុត្ត "រួចផុតពីឃោសៈ និង អឃោសៈ" គឺមិនមែនជាឃោសៈ ឬអឃោសៈឡើយ ។ ឯស្រៈទាំង ៨ តួ ខាងវេយ្យាករណ៍ភាសាសំស្ក្រឹតប្រាប់ថាជា ឃោសៈ, ខាងភាសាបាលីមិនមានប្រាប់ថាជា ឃោសៈ ឬ អឃោសៈឡើយ, ប៉ុន្តែបើទុកជាដូច្នេះក៏ដោយ គួរអ្នកសិក្សាអក្សរសាស្ត្រយល់ថាជា ឃោសៈ តាមវេយ្យាករណ៍សំស្ក្រឹតចុះ ព្រោះស្រៈទាំង ៨ តួនោះ មានសំឡេងគឹកកងតាមធម្មតារបស់ខ្លួនស្រាប់ ។

## អក្ខរប្បភេទ

បែកជាគូ ៗ គ្នានៃសម្លេងអក្ខរៈ ដែលមានសូរទទៃពីគ្នា ហៅថា អក្ខរប្បភេទ, បើរាប់ជាគូមាន ៥ គូ បើរាប់ពយមាន ១០ គឺ សិថិល និង ធនិត ជាគូ ១, ទីឃៈ និង រស្សៈ ជាគូ ១, គរុ និង លហុ ជាគូ ១,

និគ្គហិត នឹង វិមុត្ត ជាគូ១, សម្ពន្ធៈ នឹង វវត្ថិតៈ ជាគូ១ (ត្រូវជា ៥ គូ ឬ ១០ ភយ) ។

## សិថិល នឹង ធនិត

អក្ខរៈ ១០ តួ (កង់វគ្គ) គឺ កគ, ចជ, ដឌ, តទ, បព នេះជា សិថិល "មានសម្លេងធូរ" គឺមានសម្លេងសុទ្ធឥតមានសំឡេងអក្សរ ហ លាយផ្សំផងទេ ។ អក្ខរៈ ១០ តួ (កង់វគ្គដែរ) គឺ ខឃ, ឆឈ, ឋឍ, ថធ, ផភ នេះជា ធនិត "មានសម្លេងតឹង" គឺមានសំឡេងអក្សរ ហ លាយផ្សំផង ។ –

## សិថិល ផ្សំនឹង ហ បង្កើតបានជា ធនិត

| សិថិល | សិថិល នឹង ហ | បង្កើតជា ធនិត | សំឡេងធនិត |
|---|---|---|---|
| ក | ក + ហ | ខ | ក្ហ (១) |

១ បើអ្នកសិក្សាចង់សង្កេតសំឡេងអក្សរធនិតទាំងនេះឲ្យប្រាកដនោះ ត្រូវថាផ្ដួលសំឡេងពីអក្សរ សិថិល ទៅផ្សំនឹងអក្សរ "ហ" សម្រួលសំឡេងសិនថា ក‿ហ= ក្ហ (ខ) ។ល។ ព‿ហ= ព្ហ (ភ) គឺជម្រាលសំឡេងពី "ក" ទៅ "ហ" ។ល។ ពី "ព" ទៅ "ហ" ហើយសឹមក្រសោបផ្ដាច់សំឡេងអក្សរទាំងពីរតួឲ្យទៅជាសម្លេងតែមួយ ។ ទំនងនេះ ជាការងាយក្នុងដំណើរសង្កេតសំឡេង សិថិល នឹង ធនិត ។

| | | | |
|---|---|---|---|
| គ | គ + ហ | ឃ | គ្ហ |
| ច | ច + ហ | ឆ | ច្ហ |
| ជ | ជ + ហ | ឈ | ជ្ហ |
| ដ | ដ + ហ | ឋ | ដ្ហ |
| ឌ | ឌ + ហ | ឍ | ឌ្ហ |
| ត | ត + ហ | ថ | ត្ហ |
| ទ | ទ + ហ | ធ | ទ្ហ |
| ប | ប + ហ | ផ | ប្ហ |
| ព | ព + ហ | ភ | ព្ហ |

# សេចក្ដីពន្យល់

អក្សរ ប្រ ជាកណ្ឋជៈតាមឋាន-ករណៈរបស់ខ្លួន ក៏ពិតមែន ប៉ុន្តែដល់មកផ្សំជាមួយនឹងអក្សរ សិថិល ដែលមានឋាន-ករណៈត្រូវគ្នានឹងខ្លួនក្ដី ផ្សេងគ្នាពីខ្លួនក្ដី ក៏គ្រាន់តែជាជំនួយនាំអក្សរសិថិលនោះឲ្យក្លាយទៅជាអក្សរ ធនិត មានសម្លេងតឹងខ្លាំងជាងប្រក្រតីដើមរបស់ខ្លួនប៉ុណ្ណោះ ឯឋាន-ករណៈរបស់អក្សរទាំងនោះ ក៏នៅនឹងទៀងទាត់ តាមកំណើតដើមរបស់ខ្លួន ៗ ដូចដែល អក្សរ ប្រ មិនមែនទាញសម្លេងឲ្យក្លាយតាមអំណាចខ្លួនទេ ដ្បិតអក្សរធនិត ទាំងនោះសុទ្ធតែមានអក្សរ សិថិល របស់ខ្លួន ៗ ជាគោលស្រាប់ហើយ ។

ឯស្រៈ ៨ តួ, អក្សរ វគ្គៈ ៥ តួ នឹងអក្សរ អវគ្គ ៨ តួ រួមជា ២១ តួនេះ មិនរាប់បញ្ចូលក្នុងពួក សិថិល-ធនិត ទេ ព្រោះឥតមានកំណត់ពីសំឡេងធូរតឹងតាមលំដាប់គូឡើយ ។

## ទីឃៈ នឹង រស្សៈ

បណ្ដាស្រៈទាំង ៨ នោះ, ស្រៈមានសម្លេងវែង ៥ តួ គឺ អា ឦ ឩ, ឯ ឱ នេះ ទោះប្រើជាស្រៈពេញតួក្ដី ជាស្រៈផ្សំជាមួយនឹងព្យញ្ជនៈក្ដី ហៅថា ទីឃៈ "មានសម្លេងវែង" ។ ស្រៈមានសម្លេងខ្លី ៣ តួគឺ អ ឥ ឧ

នេះ នោះប្រើជាស្រៈពេញតួក្តី ជាស្រៈផ្សំជាមួយនឹងព្យញ្ជនៈក្តី ហៅថា រស្សៈ "មានសម្លេងខ្លី" ។ មួយទៀត ស្រៈទីឃៈ ៣ តួគឺ អា ឯ ឱ បើមានអក្សរតម្រួតនៅពីខាងចុង ត្រូវពោលឲ្យមានសូរសម្លេងស្រដៀងនឹង រស្សៈ ដូចជា ស្វាក្ខាតោ, មេត្តា, សេយ្យោ, ឱត្តប្បំ ជាដើម ។

## គរុ នឹង លហុ

ស្រៈទីឃៈនោះក្តី ស្រៈរស្សៈដែលមានអក្សរតម្រួតនៅពីខាងចុងក្តី និគ្គហិតក្តី ហៅថា គរុ "ឃ្ងរ, ធ្ងន់" ។ ស្រៈរស្សៈសុទ្ធ ហៅថា លហុ "ស្រាល, រហ័ស" ។

## និគ្គហិត នឹង វិមុត្ត

និគ្គហិតមានសំឡេង ២ យ៉ាងគឺ សម្លេងជា "អ័ង" ដូចជា យំ តំ (យ៉ុង, ត័ង) នេះ ហៅថា អនុនាសិកន្តៈ; សម្លេងជា "អ័ម" ដូចជា យំ តំ ( យ៉ុម, ត័ម ) នេះ ហៅថា មការន្តៈ ។ សម្លេងទាំង ២ យ៉ាងនេះ ប្រើបាន ដូចគ្នា ប៉ុន្តែសព្វថ្ងៃនេះ ច្រើនប្រើតែអនុនាសិកន្តៈ ។ អក្សរដែលកាលណាសូត្រ ឬអាន ត្រូវបង្អើបមាត់ឲ្យលើស

ជានប្រែកតិបន្តិច ដូចជា បុរាណា, ឯសា, ឱរាទោ ជាដើមនេះ ហៅថា វិមុត្ត "បង្ហើបមាត់បញ្ចេញសម្លេង" ។

## សម្ពន្ធៈ នឹង វិគ្គិតៈ

បាលីដែលចងឬតភ្ជាប់គ្នាជាបទសន្ធិ ដូចជា តុណ្ហី អស្ស តភ្ជាប់គ្នាជា តុណ្ហស្ស, តត្រ ឥមេ ជា តត្រិមេ, តត្ថ អាយស្មន្តោ ជា តត្ថាយស្មន្តោ ជាដើម ហៅថា សម្ពន្ធៈ "បទដែលចងភ្ជាប់" ។ បទបាលីដែលញែកចេញពីបទសន្ធិ ដូចជា តុណ្ហី អស្ស, តត្រ ឥមេ, តត្ថ អាយស្មន្តោ មិនចងភ្ជាប់ជា តុណ្ហស្ស, តត្រិមេ, តត្ថាយស្មន្តោ ដូច្នេះជាដើម ហៅថា វិគ្គិតៈ "បទញែក" ។

## អធិប្បាយសង្ខេប

អក្ខរប្បភេទនេះ ជាគោលសំខាន់បំផុតក្នុងអក្សរសាស្ត្រ ទោះអក្សររបស់ជនជាតិណាភាសាណា ក៏សុទ្ធតែមានអក្ខរប្បភេទជាគោលដូចគ្នា ព្រោះជាគ្រឿងបញ្ជាក់សូរសំឡេងសំដីភាសាទីមួយ ៗ ។

គន្ថព្រះវិន័យ មានសេចក្ដីបញ្ជាក់ថា បណ្ដាអក្ខរប្បភេទទាំង ៥ គូនោះ ត្រូវអ្នកសូត្រ ឬអ្នកអានប្រយ័ត្នកុំឲ្យក្លាត់គូណាមួយ, ប៉ុន្តែដែលត្រូវប្រយ័ត្នយ៉ាងម៉ឺងម៉ាត់កុំឲ្យក្លាត់ឲ្យសោះនោះ តែ ២ គូ គឺ សិថិល–ធនិត នឹង និគ្គហិត–វិមុត្ត ដ្បិតគូទាំង ២ នេះ សំខាន់ជាង ៣ គូឯទៀត, កាលបើសូត្រ ឬអានក្លាត់ ទោះសិថិល ជាធនិត ឬធនិតជាសិថិលក្ដី និគ្គហិតជាវិមុត្ត ឬវិមុត្តជានិគ្គហិតក្ដី យ៉ាងនេះទៅជាវិបត្តិខុសពេញទី ហៅថា អក្ខរវិបត្តិ ប្រែការពុំកើតឡើយ ។ ការក្លាត់នោះ ខាងភាសាបាលី, សិថិល ជាធនិត ដូចជា សុណាតុ ក្លាត់ជា សុណាថុ, គាគោ ក្លាត់ជា ឃាឃោ: ធនិត ជាសិថិល ដូចជា ខមតិ ក្លាត់ជា កមតិ, ភន្តេ ក្លាត់ជា ពន្តេ ជាដើម ។ បើធៀបនឹងភាសាខ្មែរ, សិថិលជាធនិត ដូចជា គុំ ក្លាត់ជា ឃុំ, គោក ក្លាត់ជា ឃោក; ធនិត ជាសិថិល ដូចជា ឃា ក្លាត់ជា គា, ឃោក ក្លាត់ជា គោក ជាដើម ។ និគ្គហិត ជាវិមុត្ត ឬវិមុត្ត ជានិគ្គហិត, ខាងភាសាបាលី, និគ្គហិត ជាវិមុត្ត ដូចជា បត្តកល្លំ ក្លាត់ជា បត្តកល្លា; វិមុត្តជានិគ្គហិត ដូចជា ឯសា ញត្តិ ក្លាត់ជា ឯសំ ញត្តិ ឬ ឯសញ្ញត្តិ ជាដើម ។ បើធៀបនឹងភាសាខ្មែរ, និគ្គហិតជាវិមុត្ត ដូចជា ដំណាំ ក្លាត់ជា ដាណា; វិមុត្តជានិគ្គហិត ដូចជា ញាណ ក្លាត់ជា ញំណំ ជាដើម ។ ដូច្នេះ ហៅថា អក្ខរៈវិបត្តិ “ក្លាត់អក្ខរៈ” ប្រែការ

ពុំកើតឡើយ ។

ឯអក្ខរប្បភេទ ៣ គូក្រៅពីនេះ ក៏ត្រូវតែប្រយ័ត្នកុំឲ្យភ្លាត់ដែរ ប៉ុន្តែបើបែរជាមានភ្លាត់ខ្លះ ដូចជា សុណោតុ ភ្លាត់ជា សុណាតុ ( ទីឃៈជារស្សៈ ) ; ឆក្ខមតិ ភ្លាត់ជា ឆ ខមតិ ( គរុជាលហុ ) ; យស្សាយស្មតោ ភ្លាត់ជា យស្ស អាយស្មតោ (សម្ពន្ធៈជាវវត្ថិតៈ) ដូច្នេះជាដើម ក៏មិនរាប់ថាជាវិបត្តិពេញទីទេ គង់រាប់ថានៅយកជាការបាន គ្រាន់តែបានឈ្មោះថាសូត្រ ឬអានខ្វះខាតពុំសូវទៀងទាត់ប៉ុណ្ណោះ ព្រោះនៅស្តាប់សេចក្តីបាន មិនមែនវិបត្តិដល់ទៅខូចសេចក្តីទេ ។ ប៉ុន្តែបើទុកជាដូច្នេះក៏ដោយ, ទោះភាសាបាលីក្តី ភាសាសម្រាប់ជាតិក្តី អ្នកសិក្សាត្រូវតែហាត់ព្យាមសូត្រអានទំនិយាយស្តីឲ្យត្រឹមត្រូវតាមខ្យល់សំឡេងអក្សរ ឲ្យបានទៀងទាត់ជាធម្ម កុំបណ្តោយឲ្យធ្លាប់មាត់ភ្លាត់ខុសឡើយ ។

ចប់ដោយសង្ខេប

សម្តេចព្រះមហាសុមេធាធិបតី

( ជ. ណ. ជោតញ្ញាណោ )

រោងពុម្ព ហង់រី
IMPRIMERIE HENRY